# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០០១ ជនស.របា

ថ្ងៃ សុក្រ ១រោច ខែ បុស្ស ឆ្នាំ វក ព.ស. ២៥៦០

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា គ.ស. ២០១៧

# របាយការណ៍បូកសរុបលទ្ធផល
# នៃការអនុវត្តការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧
# របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងសន្តិសុខជាតិយ៉ាងល្អប្រសើរ ព្រមទាំងសម្រេចបានជោគជ័យយ៉ាងធំធេងក្នុងការបន្តជំរុញការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ នាំមកនូវកិត្យានុភាពជាតិ ទាំងនៅក្នុងតំបន់ និងលើពិភពលោក។ ទន្ទឹមនឹងនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏បានរួមចំណែកអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល បានបំពេញបេសកកម្មរបស់ខ្លួនយ៉ាងសកម្មលើការដ្ឋានការងារធំៗជាច្រើន រួមមានការរៀបចំគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្ត រដ្ឋបាលទូទៅ ការងារចុះបញ្ជីដីធ្លី ទាំងការចុះបញ្ជីដំបូង ការចុះបញ្ជីបន្ត ទាំងការដោះស្រាយទំនាស់ដីធ្លី ការងារនគរូបនីយកម្មនិងសំណង់ ការងារបែងចែកដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រ អតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ និងជូនគ្រួសារយោធិនតាមបណ្តោយព្រំដែនទិសខាងលិចនិងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ការងារលំនៅឋាន និងការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរដើម្បីឱ្យស័ក្តិសមជាឆ្នេរស្អាតបំផុតក្នុងនាមជាសមាជិកក្លឹបឆ្នេរស្អាតបំផុតនៅលើពិភពលោក។

## II- លទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៦

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ផ្នែក គ្រប់ថ្នាក់របស់ក្រសួងបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវ និងមនសិការវិជ្ជាជីវៈខ្ពស់ ដោយបានសម្រេចស្នាដៃនិងសមិទ្ធផលការងារធំៗជាច្រើន ដូចខាងក្រោម÷



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

## ១-ការងារអភិវឌ្ឍស្ថាប័ន

### ១.១-ការងារគ្រប់គ្រងមន្ត្រី

ក្រសួងមានមន្ត្រីរាជការសរុបចំនួន **៣.០២៦** នាក់ (ស្ត្រី ៤៥០ នាក់) ក្នុងនោះថ្នាក់កណ្តាលមានចំនួន៦៩៧ នាក់ (ស្ត្រី ១៣៤ នាក់) ថ្នាក់មន្ទីរមានចំនួន ៩៨៥ នាក់ (ស្ត្រី ១៨៨ នាក់) ថ្នាក់ការិយាល័យភូមិបាល ក្រុង-ស្រុក-ខណ្ឌ មានចំនួន **១.៣៤៤** នាក់ (ស្ត្រី ១២៨ នាក់) ក្នុងនោះមន្ត្រីជាជនពិការចំនួន ៣៩ នាក់ (ស្ត្រី ០៦នាក់)។ ក្នុងចំណោមមន្ត្រីរាជការជាស្ត្រីទាំង **៤៥០** នាក់ មានមុខតំណែងចាប់ពីរដ្ឋលេខាធិការរហូតដល់អនុការិយាល័យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានចំនួន **១៥៨** នាក់ ស្មើនឹង ៣៥% នៃចំនួនមន្ត្រីរាជការជាស្ត្រីសរុប។

លទ្ធផលក្នុងឆ្នាំ ២០១៦ សម្រេចបាន÷

- ទទួលបានការយល់ព្រមពី**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**ផ្តល់ក្របខ័ណ្ឌពិសេសជូនដល់មន្ត្រីជាប់កិច្ចសន្យាបម្រើការងារវាស់វែងដីមានលក្ខណៈជាប្រព័ន្ធនៃអនុកម្មវិធីរដ្ឋបាល ដីធ្លី ចំនួន **១១១ នាក់** ចូលក្របខ័ណ្ឌក្រសួង
- បានដំឡើងឋានៈ តែងតាំងមុខតំណែង ប្រគល់ភារកិច្ច សម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន **១៣០** នាក់ (ស្ត្រី ២២ នាក់)
- បានផ្តល់នីត្យានុកូលភាពដល់ការតែងតាំងមុខតំណែង ប្រគល់ភារកិច្ច និងផ្លាស់ប្តូរភារកិច្ចតំណែងមន្ត្រីរាជការនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត សរុបចំនួន **៧២** នាក់ (ស្ត្រី ០២ នាក់)
- បានរៀបចំសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន **២.១៩៨** នាក់ សម្រាប់ឆ្នាំ២០១៦
- បានផ្លាស់ប្តូរទីកន្លែងការងារមន្ត្រីរាជការសរុបចំនួន **៦៤** នាក់ (ស្ត្រី ០៥នាក់)
- បានផ្ទេរមន្ត្រីរាជការបញ្ចូលក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន **៤១** នាក់ (ស្ត្រី ០៥ នាក់) និងបានផ្ទេរមន្ត្រីរាជការចេញពីក្របខណ្ឌក្រសួង ចំនួន **០២** នាក់
- បានរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មី ឆ្នាំ ២០១៦ ចំនួន **៩៤** នាក់ (ស្ត្រី ២៤ នាក់)
- បានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន **៣០** នាក់ និងលុបឈ្មោះចេញពីក្របខណ្ឌចំនួន **២៣** នាក់ (ស្ត្រី ០១ នាក់)
- បានអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន **៤៣** នាក់ មន្ត្រីរាជការសម្រាកលំហែមាតុភាពចំនួន **០៦** នាក់ និងសម្រាកព្យាបាលជំងឺចំនួន **១១** នាក់ (ស្ត្រី ០១ នាក់)។

### ១.២-ការងារផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច

#### ក-ការងារផែនការ

- បានរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកាទាំង ៥ ចំណុះឱ្យក្រសួង ដើម្បីធានាបាននូវភាពជាម្ចាស់នៃកម្មវិធីដោយផ្សារភ្ជាប់រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម

- បានអនុវត្ត និងគ្រប់គ្រងថវិកាកម្មវិធីស្របតាមសូចនាកររបស់កម្មវិធីនីមួយៗ និងផ្អែកទៅលើសកម្មភាព លទ្ធផល និងសមិទ្ធផលការងារ
- បានអនុវត្តការបើកផ្តល់ប្រាក់បៀវត្ស និងថវិកានានាដែលត្រូវបើក ឬទូទាត់ជូនមន្ត្រីរាជការតាមរយៈប្រព័ន្ធធនាគារ ស្របទៅនឹងបទដ្ឋានគតិយុត្តជាធរមាន និងបានទាន់ពេលវេលា។

**ខ-ការងារចំណូល**

ក្រសួងបានប្រមូលចំណូលចូលថវិកាជាតិសរុបមានចំនួន **២៨៦.៩៨៩.៩០៩.៦២០** រៀល គិតទាំងចំណូលពីការផ្ទេរអចលនទ្រព្យរួមមាន÷

១-ចំណូលពីសេវាសុរិយោដីមានចំនួន **៣២.២១៣.៦០៩.០៩៣** រៀល ក្នុងនោះ÷

- ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ចំនួន **៧.៨២៣.៨៦៨.២១០** រៀល
- ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ចំនួន **២៤.៣៨៩.៧៤០.៨៨៣** រៀល

២-ចំណូលពីសេវាសំណង់ មានចំនួន **១១.៦៨៧.៤១២.៦០០** រៀល

៣-ចំណូលពីការជួលទីតាំងរោងចក្រ សហគ្រាស មានចំនួន **២៧២.២៣៤.០៦០** រៀល

៤-ចំណូលពីពន្ធលើការផ្ទេរអចលនទ្រព្យ ដែលប្រមូលដោយអង្គភាពពន្ធដារ បានចំនួន **២៤២.៨១៦.៦៥៣.៨៦៧** រៀល។

**១.៣. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំផ្សព្វផ្សាយ**

- បានបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់ពិសេសមធ្យមសុរិយោដី **០១** វគ្គ ដែលមានសិក្ខាកាមចំនួន **៣៦** នាក់ (ស្ត្រី ០៤ នាក់) និងថ្នាក់បរិញ្ញាបត្ររងរៀបចំដែនដីចំនួន **០១** វគ្គ ដែលមានសិក្ខាកាមចំនួន ២៤ នាក់
- បានបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងវគ្គផ្សព្វផ្សាយពាក់ព័ន្ធនឹងជំនាញការងាររបស់ក្រសួងចំនួន ៩០ វគ្គ សិក្ខាកាមសរុប **១១.៤៦០** នាក់ (ស្ត្រី ១.៤០៣ នាក់) ក្នុងនោះ÷
  - ច្បាប់ គោលនយោបាយដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ — **១៤** វគ្គ សិក្ខាកាមសរុប **១.៦៩០** នាក់
  - ការងារសុរិយោដី — **១៨** វគ្គ សិក្ខាកាមសរុប **២.០១៣** នាក់
  - ការងារសំណង់ — **១៥** វគ្គ សិក្ខាកាមសរុប **២.៥៨៩** នាក់
  - ការងាររៀបចំដែនដីនិងនគរូបនីយកម្ម — ០៣ វគ្គ សិក្ខាកាមសរុប **២៥៧** នាក់
  - ការងារលំនៅឋាន — **១៥** វគ្គ សិក្ខាកាមសរុប **៣.១៦៥** នាក់
  - សេវាសាធារណៈ — ០៤ វគ្គ សិក្ខាកាមសរុប **៣៥១** នាក់
  - ការងារផែនការថវិកា — ០៤ វគ្គ សិក្ខាកាមសរុប **៥៤៥** នាក់
  - ការពង្រឹងសមត្ថភាពគ្រប់គ្រងទិន្នន័យ — ០៥ វគ្គ សិក្ខាកាមសរុប **៥១៣** នាក់
  - ការងារយេនឌ័រ — ១០ លើក សិក្ខាកាមសរុប **២៧៧** នាក់

- បានបញ្ជូនមន្ត្រីចូលរួមបន្តការសិក្សា វគ្គបណ្តុះបណ្តាល សិក្ខាសាលានៅបរទេសចំនួន ៤២ នាក់ (ស្ត្រី ០៥ នាក់) និងក្នុងប្រទេសចំនួន ១០២ នាក់ (ស្ត្រី ០៧ នាក់)។

### ១.៤- ការងារសវនកម្ម

- ចុះធ្វើសវនកម្មបានចំនួន ៣១អង្គភាព គឺនៅអង្គភាពថ្នាក់កណ្តាល ០៦ អង្គភាព និងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ២៥ រាជធានី ខេត្ត
- បានចុះពិនិត្យ និងកែលម្អចំណុចមួយចំនួននៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន ១២ គឺខេត្តស្ទឹងត្រែង រតនគីរី កំពង់ធំ ព្រះវិហារ ព្រៃវែង ស្វាយរៀង កំពង់ចាម កណ្តាល តាកែវ កំពង់ស្ពឺ កំពត និងខេត្តកែប។

### ១.៥- ការងារអធិការកិច្ច

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យរដ្ឋបាល និងសេវាសាធារណៈចំនួន ១០៩ លើក គឺនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន ២៤ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកចំនួន ៨៥
- បានចុះធ្វើអធិការកិច្ចតាមពាក្យបណ្តឹង និងប្រតិបត្តិកិច្ចការតាមប្រធានស្ថាប័នប្រគល់ជូន ចំនួន ១០០ ករណី
- បានចុះធ្វើអធិការកិច្ចលើការងារបច្ចេកទេសសុរិយោដីចំនួន ១១៤ លើក គឺនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី/ខេត្ត ចំនួន ២៥ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ចំនួន ៨៩ ដែលមានមន្ត្រីចូលរួមទទួលការណែនាំបន្ថែមសរុបចំនួន ៤២០ នាក់ (ស្ត្រី ៨០ នាក់)។

### ១.៦- ការគាំទ្រការងារវិមជ្ឈការនិងវិសហមជ្ឈការ

- បាន និងកំពុងសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការបន្តអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយទាំង ៣៦ ក្រុង ខណ្ឌ
- បាន និងកំពុងពិនិត្យកែសម្រួលមុខសញ្ញា និងតម្លៃសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បាន និងកំពុងសហការជាមួយអគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងការប្រមូលពន្ធប្រថាប់ត្រាពីការផ្ទេរកម្មសិទ្ធិ និងការចុះបញ្ជីដំបូង
- បាន និងកំពុងសហការជាមួយរដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ។

## ២- ការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ក្របខណ្ឌគោលនយោបាយនិងក្របខណ្ឌគតិយុត្តសម្រេចបានក្នុងឆ្នាំ ២០១៦ រួមមាន÷

- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងលើការវាស់វែង និងការផលិតផែនទី និងការធ្វើអាជីវកម្មការវាស់វែង
- អនុក្រឹត្យ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា ៩ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា ៦ មាត្រា ៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- ប្រកាសអន្តរក្រសួង ស្តីពីការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មជ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី
- ប្រកាសរួម ស្តីពីការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរិមាផ្លូវការ
- ប្រកាសរួម ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តលើការប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរិមាផ្លូវការ
- សេចក្តីសម្រេច ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអភិវឌ្ឍនិងផ្សព្វផ្សាយគោលនយោបាយ និងច្បាប់
- សេចក្តីណែនាំ ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីដែលត្រូវដាក់បញ្ចូលជាដីកម្មសិទ្ធិសមូហភាព ឬដែលត្រូវកាត់ចេញពីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជានីតិបុគ្គលរួច
- បាន និងកំពុងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

### ៣-ការផ្តល់សេវាសាធារណៈតាមច្រកចេញ ចូលតែមួយ

- មានគម្រោងស្នើសុំចំនួន **៨៧៧** គម្រោង
- គម្រោងដែលបានអនុញ្ញាតមានចំនួន **៩៨៨** គម្រោង
- ចំណូលសរុបទទួលបានពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ សរុបមានចំនួន **៤៣.៩០១.០២១.៦៩៣** រៀល រួមមាន÷ សេវានៅថ្នាក់កណ្តាលមានចំនួន **៦.៧៦៧.០០៦.០០០** រៀល និងថ្នាក់ខេត្តមានចំនួន **៣៧.១៣៤.០១៥.៦៩៣** រៀល

### ៤-ការងាររដ្ឋបាលដីធ្លី

#### ៤.១-ការងារចុះបញ្ជីដំបូង

ក្រសួងបានចេញប័ណ្ណកម្មសិទ្ធិដីបានចំនួន **៣១៦.០៨១** ប័ណ្ណ ក្នុងនោះរួមមាន÷

- **កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ÷** បានប្រកាសកំណត់តំបន់វិនិច្ឆ័យចំនួន **១៥០ ភូមិ** បញ្ចូលទិន្នន័យចំនួន **២៥១.៥២៤** ប័ណ្ណ និងចេញប័ណ្ណជូនប្រជាពលរដ្ឋមានចំនួន **២៩៥.២៧១** ប័ណ្ណ
- **ការចុះបញ្ជីតាមរយៈបទបញ្ជាលេខ ០១** សម្រេចបាន **១៨.០២០** ប័ណ្ណ
- **ការចុះបញ្ជីដាច់ដោយដុំ** សម្រេចបាន **២.៦១៤** ប័ណ្ណ
- **ការចុះបញ្ជីដីសម្ភូហភាពសហគមន៍ជនជាតិដើមភាគតិច** សម្រេចបាន **៦០** ប័ណ្ណ (០៣ សហគមន៍)
- **ការចុះបញ្ជីដីរដ្ឋ** សម្រេចបាន **១១៦** ប័ណ្ណ

## ៤.២- ការងារចុះបញ្ជីបន្ត

- ចុះបញ្ជីផ្ទេរសិទ្ធិ ចំនួន **២៦.៤៨៩** ប័ណ្ណ
- ចុះបញ្ជីប្រាតិភោគ (ដាក់បញ្ចាំ/ហ៊ីប៉ូតែក) ចំនួន **១៧.៩២១** ប័ណ្ណ

បើគិតពីពេលចាប់ផ្តើម រហូតដល់ដំណាច់ឆ្នាំ ២០១៦ សម្រេចចែកប័ណ្ណ **៤.៤៥១.៨១៧** ក្បាលដី ស្មើនឹង **៦៣,៦%** នៃក្បាលដីប៉ាន់ស្មានសរុប **៧** លានក្បាលដី។ លទ្ធផលនេះ បើគិតធៀបតាមផែនការដែលត្រូវសម្រេចឱ្យបានរហូតដល់ដំណាច់ឆ្នាំ ២០១៦ ឃើញថាលើសផែនការ **១,៦ %មានដូចខាងក្រោម÷**

- **ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ** សម្រេចបាន **៣ ២០២ ៩៥៨** ប័ណ្ណ។
- **ការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ ០១បប** សម្រេចបាន **៦៣៧ ១៣០** ប័ណ្ណ។
- **ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ**សម្រេចបាន **៦១០ ៤៧០** ប័ណ្ណ។
- **ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច** សម្រេចបាន **១៤** សហគមន៍ ស្មើនឹង **៤៥៩** ប័ណ្ណ ទំហំ **១.២៣៥.៧៧៩** ហិកតា ស្មើ **១.៤៧៨** គ្រួសារ។
- **ការចុះបញ្ជីដីរដ្ឋ ដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច និងជួលអចិន្ត្រៃយ៍** សម្រេចបាន ៨០០ ប័ណ្ណ ទំហំប្រមាណ ៤០ ម៉ឺនហិកតា។

## ៤.៣- ការងារវាស់វែង និងភូមិសាស្ត្រ

**ក- ការផលិតអ័រតូផូតូ ÷** បានផលិតអ័រតូផូតូព័ណ៌ធម្មជាតិមាត្រដ្ឋាន ១/៤០០០ នៅតំបន់មួយចំនួននៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង ខេត្តកំពង់ធំ និងខេត្តកំពង់ចាម សរុបចំនួន **៤៤៣** សន្លឹក ស្មើនឹង **១.៦៦៨** គ.ម$^{២}$។

**ខ- ការផ្តល់ទិន្នន័យអ័រតូផូតូ ÷** បានផ្តល់ទិន្នន័យអ័រតូផូតូព័ណ៌ និងពីរូបថតពីលើអាកាសស-ខ្មៅ មាត្រដ្ឋាន ១/៤០០០ សរុបចំនួន **៣២៥** សន្លឹក ស្មើនឹង **១.០៣០** គ.ម$^{២}$ ជូនដល់ក្រុមការងារចុះបញ្ជីដីធ្លីនៅរាជធានីភ្នំពេញ ខេត្តព្រៃវែង កំពង់ចាម និងខេត្តតាកែវ ។

**ខ- ការងារបោះពុម្ពផែនទី ÷** បានបោះពុម្ពប្លង់សុរិយោដី រូបថតអ័រតូផូតូ និងបញ្ជីឈ្មោះម្ចាស់ដីមានចំនួនសរុប **១.៩៩២** សន្លឹក សម្រាប់ជូនក្រុមការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនៅខេត្តក្រចេះ ស្វាយរៀង ព្រះវិហារ កំពង់ចាម សៀមរាប បាត់ដំបង ព្រៃវែង កោះកុង កំពង់ធំ និងខេត្តកំពត ។

គ- ការងារធ្វើបច្ចុប្បន្នភាពទីតាំងនាមភូមិសាស្ត្រ និងស្រង់ទិន្នន័យភូមិសាស្ត្រ

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យបញ្ជីរាយនាមភូមិសាស្ត្រនៃភូមិបង្កើតថ្មីៗតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ឆ្នាំ ២០១៦ សរុបចំនួន ៧១ ភូមិ នៅខេត្តបន្ទាយមានជ័យ កំពង់ធំ ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ ប៉ៃលិន និងខេត្តត្បូងឃ្មុំ
- បានធ្វើបច្ចុប្បន្នភាពឈ្មោះឃុំ/សង្កាត់បង្កើតថ្មី សរុបចំនួន ០៤ នៅខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ
- បានធ្វើបច្ចុប្បន្នភាពការបំបែកឈ្មោះសង្កាត់ថ្មីចំនួន ០៥ នៅរាជធានីភ្នំពេញ
- បានធ្វើបច្ចុប្បន្នភាពការកែសម្រួលព្រំប្រទល់រដ្ឋបាលចំនួន ០៦ ខណ្ឌ នៅរាជធានីភ្នំពេញ
- បានធ្វើបច្ចុប្បន្នភាពលេខកូដភូមិបង្កើតថ្មីតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានចំនួន **១០៧** ភូមិ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ព្រះសីហនុ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កោះកុង និងខេត្តឧត្តរមានជ័យ
- បានចុះស្រង់ទិន្នន័យភូមិសាស្ត្រ ទីតាំងរដ្ឋបាល (សាលាស្រុក សាលាឃុំ ភូមិ មណ្ឌលសុខភាព សាលារៀន និងទីតាំងរដ្ឋបាលផ្សេងៗ) នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ សរុបចំនួន **៣.២២៦** ចំណុច។

ឃ- ការងារបច្ចេកទេស និងវាស់វែង

- បានចុះសហការជាមួយអាជ្ញាធរមូលដ្ឋានធ្វើការកំណត់ និងវាស់វែងព្រំប្រទល់រដ្ឋបាលតាមការគ្រប់គ្រងជាក់ស្តែងចំនួន ៤៧ឃុំ/សង្កាត់ នៅខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង
- បានសាងសង់ និងវាស់វែងបង្គោលរយៈកម្ពស់លំដាប់ទី៣ សរុបចំនួន ៦០ បង្គោល មានចម្ងាយ ២៧២ គីឡូម៉ែត្រ នៅខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់
- បានសាងសង់ និងវាស់វែងបណ្តាញបង្គោលប្រឹថពីវិភាគថ្នាក់ជាតិលំដាប់ទី៣ និងបណ្តាញបង្គោលពហុកោណគោល ចំនួន ៤៦៨ បង្គោល ខេត្តត្បូងឃ្មុំ បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ពោធិ៍សាត់ រតនគីរី កំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង និងខេត្តតាកែវ
- បានចូលរួមគាំទ្រវាស់វែងប្លង់គោលតំបន់ឆ្នេរសមុទ្រជាមួយក្រុមការងារគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរកម្ពុជា
- បានធ្វើកិច្ចសហប្រតិបត្តិការក្នុងការចុះអនុវត្តគម្រោងការស្តារនិងធ្វើឱ្យប្រសើរឡើងវិញបណ្តាញរយៈកម្ពស់ ដោយបានចុះដាំបង្គោលបណ្តាញរយៈកម្ពស់សរុបចំនួន **១២៤** បង្គោល នៅខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី រតនគីរី ព្រៃវែង កណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ កំពង់ស្ពឺ កោះកុង និងខេត្តព្រះសីហនុ
- ចុះណែនាំពីការប្រើប្រាស់ឧបករណ៍វាស់វែង និងការកសាងប្លង់ក្បាលដី នៅមន្ទីរ ដ.ន.ស.ស ខេត្តស្វាយរៀង ក្រចេះ ស្ទឹងត្រែង រតនគីរី ប៉ៃលិន ពោធិ៍សាត់ កែប កណ្តាល កំពង់ធំ

ឧត្តរមានជ័យ ព្រៃវែង កំពង់ឆ្នាំង បាត់ដំបង និងខេត្តបន្ទាយមានជ័យ មានមន្ត្រីចូលរួមសរុបចំនួន ២០៤ នាក់

- បានចុះពិនិត្យ និងជំរុញជម្រះបញ្ចប់ការងារសេសសល់ពីការចុះបញ្ជីបទបញ្ជា ០១ បប ខេត្តកំពង់ចាម ត្បូងឃ្មុំ មណ្ឌលគីរី រតនគីរី ស្ទឹងត្រែង ក្រចេះ និងខេត្តកោះកុង។

### ៤.៤-ការងារវិវាទដីធ្លី

#### ក- លទ្ធផលការដោះស្រាយវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី

- ដោះស្រាយបញ្ចប់ចំនួន ២៣៥ ករណី ដែលមាន **១.២៧១** គ្រួសារ ស្មើនឹងផ្ទៃដីទំហំ **១៤៥.៤** ហិកតា
- ច្រានចោលពាក្យបណ្ដឹងបន្ទាប់ពីស៊ើបអង្កេតឃើញថាខុសសមត្ថកិច្ច ចំនួន **១៣២** ករណី
- សុំដកពាក្យបណ្ដឹងចំនួន ៨០ ករណី

#### ខ- ការដោះស្រាយវិវាទដីធ្លីដោយក្រុមការងារក្រសួង

- ទទួលពាក្យបណ្ដឹង ចំនួន **៧៥៧** ករណី
- លទ្ធផលដោះស្រាយសរុបបានចំនួន **១១៥** ករណី ក្នុងនោះ ដោះស្រាយបញ្ចប់ចំនួន ៤៤ ករណី និងបានធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្ដឹង ឬ បង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធចំនួន **៧១** ករណី។

### ៤.៥-ការងារអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យសុរិយោដី

- បាននិងកំពុងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានសុរិយោដីកម្ពុជា (CCIS) តាមកម្មវិធី Free Open Source Software
- បាននិងកំពុងធ្វើការសិក្សាស្រាវជ្រាវ និងបានរៀបចំតម្លើងសាកល្បងប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យចុះបញ្ជីដីធ្លី នៅមន្ទីររាជធានី ខេត្តចំនួន ៣ (រាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តកំពង់ចាម) មកនាយកដ្ឋានតាមរយៈប្រព័ន្ធ Internet
- រៀបចំឯកសារបណ្ដុះបណ្ដាលអំពីរបៀបបញ្ចូលទិន្នន័យការចុះបញ្ជីដំបូងក្នុងប្រព័ន្ធព័ត៌មានសុរិយោដីកម្ពុជា។

## ៥-ការងាររៀបចំដែនដី និងនគរូបនីយកម្ម

### ៥.១-ការងារកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់

- បានចុះប្រមូលទិន្នន័យចំនួន ០២ លើក នៅខេត្តព្រៃវែង បាត់ដំបង ខេត្តកំពង់ស្ពឺ និង ០១ លើក នៅខេត្តមណ្ឌលគីរី ស្វាយរៀង និងខេត្តកំពង់ឆ្នាំងសម្រាប់ការកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ
- បាន និងកំពុងរៀបចំសំណុំឯកសារសេចក្ដីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ ដើម្បីស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី

- បានរៀបចំឯកសារត្រៀមសម្រាប់កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើក្របខណ្ឌអភិវឌ្ឍតំបន់ទីក្រុងជុំវិញបឹងទន្លេសាប។

## ៥.២- ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

- បាន និងកំពុងចុះប្រមូលទិន្នន័យ និងវាស់វែងការប្រើប្រាស់ដីលម្អិត ដើម្បីកសាងផែនការប្រើប្រាស់ដីចំណីឆ្នេរចំនួន ០៦ទីតាំង គឺឆ្នេរម្លប់ជ្រៃ ឆ្នេរកោះពស់ ឆ្នេរឯករាជ្យ ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ និងឆ្នេរកោះរ៉ុង ខេត្តព្រះសីហនុ
- បានបញ្ចប់ការសិក្សាផែនការប្រើប្រាស់ដីតំបន់ពយកំពេញ និងបានប្រគល់ជូនសាលាខេត្តព្រះសីហនុ
- បានចុះប្រមូលទិន្នន័យក្នុងការសិក្សាប្លង់គោល និងផែនការប្រើប្រាស់ដីលើកោះរ៉ុង និងការងារធ្មៀលដីស្បែកខ្លានៅកោះរ៉ុងជូនប្រជាពលរដ្ឋ
- បានចុះស្រង់ទិន្នន័យ និងកំណត់តំបន់ប្រើប្រាស់ដីក្នុងការដាក់តំបន់បឹងព្រែកទប់ជាតំបន់អភិរក្សទឹកសាបដោយអនុក្រឹត្យ
- បានរៀបចំ និងអនុម័តលើប្លង់ស្ថាបត្យកម្មខ្លោងច្រកចូលឆ្នេរចំនួន ០៨ នៃគម្រោងកែលម្អតំបន់ឆ្នេរខ្សាច់កំសាន្ត ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បានរៀបចំប្លង់ស្ថាបត្យកម្មតូបកម្សាន្តនៃគម្រោងកែលម្អតំបន់ឆ្នេរខ្សាច់កំសាន្ត ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បានប្រជុំពិនិត្យ និងផ្តល់ការយល់ព្រមពីគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា នូវគម្រោងចំនួន ០២ គឺ ផែនការអភិវឌ្ឍន៍ទេសចរណ៍កំពតថ្មីឆ្នាំ២០១៦-២០១៨ នៅស្រុកទឹកឈូ ខេត្តកំពត និងគម្រោងអភិវឌ្ឍន៍ French Riviera Marina ដែលមានទីតាំងនៅខេត្តកំពត និងខេត្តកែប
- បានចុះសិក្សាទីតាំង និងវាស់វែងកំណត់ទីតាំងសម្រាប់សាងសង់ខ្លោងច្រកចូលឆ្នេរឯករាជ្យ ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ ឆ្នេរម្លប់ជ្រៃ ឆ្នេរកោះពស់ និងឆ្នេរអូរឈើទាល២ និងពយកំពេញ
- បានសិក្សាសេចក្តីព្រាងផែនការប្រើប្រាស់ដីតំបន់បឹងព្រែកទប់ ក្រុងព្រះសីហនុ និងកំពុងដាក់ឆ្លងមតិគណៈកម្មាធិការអភិវឌ្ឍន៍ឆ្នេរសមុទ្រកម្ពុជា។

## ៥.៣- ការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

- បាន និងកំពុងពិនិត្យសំណុំឯកសារផែនការរៀបចំដែនដីខេត្តបាត់ដំបង និងខេត្តព្រះសីហនុ ដើម្បីស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី
- បានធ្វើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន និងកំពុងចងក្រងទិន្នន័យសម្រាប់ធ្វើការវិភាគក្នុងដំណើរការកសាងផែនការរៀបចំដែនដីខេត្តសៀមរាប។

៥.៤- ការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក និងទីប្រជុំជន

- បាន និងកំពុងគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុងចំនួន ០៦ និងទីប្រជុំជនចំនួន ០២ គឺ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្រុងកែប ខេត្តកែប ក្រុងសៀមរាប ខេត្តសៀមរាប ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្រុងកំពត ក្នុងខេត្តកំពត ក្រុងព្រៃវែង ទីប្រជុំជនស្វាយអន្ទរ និង ទីប្រជុំជនអ្នកលឿង ខេត្តព្រៃវែង
- បាន និងកំពុងគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងចំនួន ០២ ស្រុកចំនួន ០៣ គឺក្រុងកំពង់ឆ្នាំង និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្រុកបវេល ខេត្តបាត់ដំបង ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល (សហការជាមួយអង្គការ GIZ)
- បាន និងកំពុងគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកចំនួន ០៣គឺ ស្រុកលំផាត់ ស្រុកវើនសៃ ខេត្តរតនគីរី និងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- បាន និងកំពុងកសាងប្លង់លម្អិតទីប្រជុំជនស្រុកចិត្របុរី ខេត្តក្រចេះ ក្នុងក្របខណ្ឌគម្រោងរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

៥.៥- ការងារកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ- សង្កាត់

- ផែនការប្រើប្រាស់ដីនៅក្នុងឃុំទួលគគីរ ស្រុកមណ្ឌលសីមា និងឃុំតាតៃក្រោម ស្រុកកោះកុង ស្ថិតក្នុងខេត្តកោះកុង ឃុំស្នាមព្រះ ស្រុកបាកាន និងឃុំរកាត ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ ព្រមទាំងឃុំរាម និងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានត្រូវរៀបចំ និងបញ្ចប់តាមនិតិវិធី និង កំពុងដាក់ជូនក្រុមប្រឹក្សាខេត្តគោលដៅទាំង ០៣ ចុះហត្ថលេខាអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំស្រអែម និងឃុំកន្ទួត÷** បានរៀបចំបញ្ចប់សេចក្តីព្រាងបឋមស្តីពីផែនការប្រើប្រាស់ដី ដើម្បីដាក់ក្នុងកិច្ចប្រជុំពិភាក្សាឱ្យមានការឯកភាពគ្នាក្នុងក្រុមប្រឹក្សាឃុំ
- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន ៦២ (ដែលបានអនុម័តរួច)÷** បានរៀបចំលិខិតទៅក្រសួងមហាផ្ទៃដើម្បីជំរុញឱ្យអាជ្ញាធរអនុវត្តដោយដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់សម្រាប់ឆ្នាំ ២០១៧-២០២២
- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន ១៤ក្នុងខេត្តក្រចេះ ÷** បានអនុម័តរួច
- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ចំនួន ៤៣ ទីតាំងនៅខេត្តចំនួន ០៤ ដែលនៅសេសសល់÷** បានពិនិត្យដើម្បីជំរុញថ្នាក់ក្រោមជាតិបញ្ចប់។

## ៦- ការងារសំណង់

ក- កម្លាំងពលកម្មនិងប្រាក់បៀវត្ស

វិស័យសំណង់បានបង្កើតការងារជាច្រើនប្រភេទជូនប្រជាពលរដ្ឋគិតជាមធ្យមប្រមាណ ១៩០.០០០ នាក់ ទៅ ២០០.០០០ នាក់/ថ្ងៃ ក្នុងនោះរាជធានីភ្នំពេញមានចំនួនកម្មករប្រមាណពី ១៤០.០០០ នាក់ ទៅ

១៥០.០០០ នាក់/ថ្ងៃ ហើយកម្លាំងពលកម្មអាចប្រែប្រួលទៅតាមទំហំការងារជាក់ស្តែងនៅការដ្ឋានសំណង់ បើប្រៀបធៀបនឹងឆ្នាំ២០១៥ បរិមាណនៃកម្លាំងពលកម្មមានការកើនឡើងចំនួន ៣៣,៣៣ %។ តាមរយៈនៃការសិក្សាស្រាវជ្រាវតម្លៃពលកម្មសម្រាប់កម្មករគ្មានជំនាញក្នុង ១ ខែទទួលបាន ១២០ ទៅ ២០០ ដុល្លារអាមេរិក កម្មករមានជំនាញ និងមេជាងក្នុង ១ ខែទទួលបាន ៣០០ ទៅ ៤៥០ ដុល្លារអាមេរិក ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀត ក្នុង ១ ខែ ទទួលបានប្រាក់បៀវត្សពី ៣៥០ ដុល្លារអាមេរិក ទៅ ២.៥០០ ដុល្លារអាមេរិក។

**ខ- លិខិតអនុញ្ញាតសាងសង់**

- ***គម្រោងសាងសង់ទូទាំងប្រទេស:*** មានចំនួនសរុប **២.៦៣៦** គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន **១៤.៦២០.២២៥** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៨.៥៣៤.០៥៨.៣៨៩** ដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៥ មានចំនួន **២.៣០៥ គម្រោង** មានផ្ទៃក្រឡាសំណង់សរុបចំនួន **៧.៦៨៦.១១២** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៣.៣៣៨.១០៧.២១៨** ដុល្លារអាមេរិក គឺមានការកើនឡើងចំនួន **១៥៥,៦៨%** ក្នុងនោះការចេញលិខិតអនុញ្ញាតសាងសង់ដោយ ÷
  - ***សមត្ថកិច្ចក្រសួង:*** មានចំនួនសរុប **៣៥៤** គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន **១៣.០៧៥.៥១៤** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៨.០០៣.៥៣០.១៩០** ដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៥ មានចំនួន **១៨៤** គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន **៦.៦៧៨.៧២៨** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៣.០០៩.២១៧.១០៦** ដុល្លារអាមេរិក ទុនវិនិយោគមានការកើនឡើងចំនួន **១៦៥,៩៦** %
  - ***សមត្ថកិច្ចរាជធានី-ខេត្ត:*** មានចំនួនសរុប **២.២៨២** គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន**១.៥៤៤.៧១១** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៥៣០.៥២៨.១៩៩** ដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៥ មានចំនួន **២.១២១** គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន **១.០០៧.៣៨៤** ម$^2$ មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៣២៨.៨៩០.១១២** ដុល្លារអាមេរិក គឺមានការកើនឡើងចំនួន **៦១,៣០** %
- បានត្រួតពិនិត្យប្លង់គ្រឿងផ្គុំសំណង់ដែលជាសមត្ថកិច្ចរបស់ក្រសួងសរុបប្រចាំឆ្នាំ ២០១៦ មានចំនួន **៩៨** គម្រោង បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៥ មានចំនួន **៣២** គម្រោង មានការកើនឡើងចំនួន **៦៦** គម្រោង។

ជារួមសំណង់នៅទូទាំងប្រទេស គិតចាប់តាំងពីឆ្នាំ ២០០០ ដល់ខែធ្នូ ឆ្នាំ ២០១៦ បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន **៣៦.៨៥២** គម្រោង ផ្ទៃក្រឡាសំណង់សរុបចំនួន **៩៣.៩៥០.៥០៤** ម$^2$ ដែលតម្លៃប៉ាន់ស្មានទុនវិនិយោគសរុប **៣៤.២៩៧.១១៦.១៣១** ដុល្លារអាមេរិក។

គ-លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ លិខិតបិទការដ្ឋានសាងសង់ និងលិខិតអនុញ្ញាតជួសជុល

- បានផ្ដល់លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ដែលជាសមត្ថកិច្ចក្រសួងបានចំនួន **១៤៥** គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ខែធ្នូ ឆ្នាំ ២០១៦ មាន **១.៣៤៣** គម្រោង)
- បានផ្ដល់លិខិតអនុញ្ញាតបិទការដ្ឋានសាងសង់ដែលជាសមត្ថកិច្ចក្រសួងបានចំនួន **៦៣** គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ខែធ្នូ ឆ្នាំ ២០១៦ មាន **៤៦៣** គម្រោង)
- បានផ្ដល់លិខិតអនុញ្ញាតជួសជុលចំនួន **០៩** គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ខែធ្នូ ឆ្នាំ ២០១៦ មាន **១៣៧** គម្រោង)។

ឃ-ការងារចុះបញ្ជីក្រុមហ៊ុនអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់

- ចុះបញ្ជីក្រុមហ៊ុនអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់បានចំនួន **៣៦៩** ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនបរទេសមានចំនួន **១៣៧** ក្រុមហ៊ុន និងក្រុមហ៊ុនក្នុងស្រុកមានចំនួន **២៣២** ក្រុមហ៊ុន (គិតចាប់តាំងពីអនុវត្តមកដល់ខែធ្នូ ឆ្នាំ ២០១៦ មានចំនួន ១.៩៤២ ក្រុមហ៊ុន ប៉ុន្តែនៅមានសុពលភាពតែចំនួន ១.០០២ ក្រុមហ៊ុន)
- ចុះបញ្ជីរូបវន្តបុគ្គលសិក្សាគម្រោងប្លង់បានចំនួន **៥៥** នាក់ ក្នុងនោះស្ថាបត្យករខ្មែរចំនួន **៤៦** នាក់ ស្ថាបត្យករជនជាតិបរទេសចំនួន **០១** នាក់ និងវិស្វករខ្មែរចំនួន ០៨ នាក់ (គិតចាប់តាំងពីអនុវត្តមកដល់ខែធ្នូ ឆ្នាំ ២០១៦ មានចំនួន ១៣៤ នាក់ ប៉ុន្តែនៅមានសុពលភាពតែចំនួន ១១០ នាក់ ក្នុងនោះស្ថាបត្យករចំនួន ៧៩ នាក់ បរទេស ០២ នាក់ និងវិស្វករចំនួន ៣១ នាក់)។

ង-លទ្ធផលការងាររបស់គណៈស្ថាបត្យករកម្ពុជា

- បានទទួលពាក្យសុំចុះឈ្មោះក្នុងបញ្ជី និងចេញបង្កាន់ដៃសុំចុះឈ្មោះក្នុងបញ្ជីស្ថាបត្យករបានចំនួន **១០២** នាក់ (ស្រីចំនួន **១០** នាក់ និងបរទេសចំនួន **០៥** នាក់ ក្នុងនោះមានជនជាតិអង់គ្លេស កូរ៉េ ចិន និង ជប៉ុន **០២** នាក់)
- ទទួលប្រាក់ភាគទានប្រចាំឆ្នាំពីស្ថាបត្យករចុះបញ្ជីបានចំនួន **៨៧** នាក់។

## ៧-ការងារលំនៅឋាន

### ៧.១-ការងារលំនៅឋាន

- បានសហការបង្កើតក្រុមការងាររៀបចំកម្មវិធីអភិវឌ្ឍលំនៅឋានសាធារណៈតម្លៃទាបជាមួយឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានសហការជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំចុះត្រួតពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាលសាលាខេត្តត្បូងឃ្មុំ និងមន្ទីរជុំវិញខេត្ត ចំនួន **២៤** លើក
- បានសហការជាមួយអាជ្ញាធរខេត្តព្រៃវែងដើម្បីសិក្សាប្លង់គោលប្រើប្រាស់ដីទីប្រជុំជនស្វាយអន្ទរ និងក្រុងព្រៃវែង ចំនួន ០៣ លើក

- បានសហការជាមួយអាជ្ញាធរ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបន្ទាយមានជ័យ ក្នុងការចុះពិនិត្យ និងប្រមូលទិន្នន័យសំណង់បណ្តោះអាសន្ន និងស្រង់ទិន្នន័យកម្រិតប្រាក់ចំណូលរបស់ប្រជាពលរដ្ឋរស់នៅក្នុងទីតាំង តំបន់សំណង់បណ្តោះអាសន្ននៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ចំនួន ០៨ លើក
- បានសហការជាមួយអាជ្ញាធរនិងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង ព្រះសីហនុ សៀមរាប កំពង់ចាម មណ្ឌលគិរី និងខេត្តរតនគិរី ក្នុងការប្រមូលទិន្នន័យចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសលំនៅឋានសម្រាប់ប្រជាពលរដ្ឋ មានប្រាក់ចំណូលមធ្យមទាប និងក្រុមជនងាយរងគ្រោះ
- បានចុះពិនិត្យ និងសិក្សាទីតាំងសាងសង់ផ្ទះគំរូដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅខេត្តសៀមរាប និង ខេត្តបាត់ដំបង ចំនួន ០២ លើក
- បានសហការជាមួយអាជ្ញាធរខេត្តបាត់ដំបង និងខេត្តព្រះសីហនុ ក្នុងការចុះប្រមូលទិន្នន័យសម្ភារៈសំណង់ និងតម្លៃពលកម្មដែលពាក់ព័ន្ធនឹងការធ្វើបទដ្ឋានបច្ចេកទេសលំនៅឋានចំនួន ០១ លើក
- បានចុះអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការលំនៅឋានសម្រាប់មនុស្សជាតិកម្ពុជា
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការការងាររវាងអគ្គនាយកដ្ឋានលំនៅឋាន និងអង្គការការីតាស់កម្ពុជា
- បានធ្វើទំនាក់ទំនងជាមួយក្រសួងផែនការ និងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសធនាគារក្នុងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រី
- បានសម្របសម្រួលការចុះស្រង់ព័ត៌មានប្រជាពលរដ្ឋជាម្ចាស់ចំណែកឯកជន នៃអគារសហកម្មសិទ្ធិ "អគារប៊ូឌីញស"
- បានសហការជាមួយក្រុមហ៊ុន ARAKAWA រៀបចំគម្រោងអភិវឌ្ឍន៍ឡើងវិញអគារប៊ូឌីញ "ស"
- បានសហការជាមួយក្រុមហ៊ុន Worldbridgeland Co. Ltd. ក្នុងការរៀបចំគម្រោងលំនៅឋានសាធារណៈ មានតម្លៃសមរម្យសម្រាប់គ្រួសារមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងប្រជាជនមានប្រាក់ចំណូលមធ្យម និងប្រាក់ចំណូលទាប
- បានសហការជាមួយអង្គការ JICA ក្នុងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអគ្គនាយកដ្ឋានលំនៅឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

## ៧.២- កម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

- បានសហការជាមួយអាជ្ញាធរស្រុក និងមន្ទីរសុខាភិបាលចុះពិនិត្យ និងកំណត់ទីតាំងគ្រោងសាងសង់មណ្ឌលសុខភាពសម្រាប់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងបានជំរុញអ្នក

ទទួលសម្បទានដីសង្គមកិច្ចឱ្យចូលទៅដាំដុះដំណាំលើដីកសិកម្ម នៅភូមិជ្រៃសែនជ័យ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

- បានចុះសម្របសម្រួល និងដោះស្រាយទំនាស់ព្រំដីកសិកម្មចំនួន ០២ គ្រួសារ ដល់គ្រួសារដែលទទួលបានសម្បទានដីសង្គមកិច្ច និងបានសហការជាមួយអាជ្ញាធរឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដោះស្រាយដីកសិកម្មចំនួន ២៣ ឡូត៍ ស្មើនឹង ២៣ ហិកតា ដែលជនអនាធិបតេយ្យចូលទន្រ្ទានកាន់កាប់
- បានចុះពិនិត្យទីតាំងជីកស្រះសហគមន៍ទំហំ ៤០ម x៦០ម x២ម ក្នុងតំបន់សម្បទានដីសង្គមកិច្ច ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលជាមូលនិធិឃុំតាំងសំរោង និងបានសហការជាមួយអាជ្ញាធរ និងអ្នកទទួលបានសម្បទានដីសង្គមកិច្ចក្នុងការឈូសឆាយដីទំហំ ៤,២ ហិកតាសម្រាប់គ្រោងសាងសង់វត្តអារ៉ាម
- បានពិនិត្យបញ្ជីឈ្មោះជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារចំនួន ២៣ គ្រួសារ និងផ្តល់ការណែនាំដល់ពួកគាត់ពាក់ព័ន្ធឯកសារដែលនឹងត្រូវភ្ជាប់ជាមួយនៅពេលពិធីចាប់ឆ្នោតជ្រើសរើសដីឡូត៍លំនៅឋាន និងកសិកម្ម
- បានសហការជាមួយក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី រៀបចំផែនការប្រើប្រាស់ដី និងប្លង់បែងចែកដីឡូត៍លំនៅឋាន និងកសិកម្មដែលនៅសល់ ស្ថិតនៅក្នុងឃុំ ត្រពាំងក្រហម ស្រុកកូនមុំ សម្រេចបាន ៧០%
- បានប្រមូលគល់បញ្ជីសន្លឹកឆ្នោត បញ្ជីឈ្មោះគ្រួសារដែលបានមកចាប់ឆ្នោតចំនួន ១២៩ សន្លឹក រូបថតអ្នកចាប់ឆ្នោតចំនួន ១២៣ សន្លឹក រូបថតដីឡូត៍លំនៅឋានផ្ទះថ្មចំនួន ៤០ ខ្នង ប្រវត្តិរូបគ្រួសារដែលទទួលសម្បទានដីសង្គមកិច្ចចំនួន ១៥១ គ្រួសារ និងបានចុះត្រួតពិនិត្យស្ថានភាពរស់នៅរបស់គ្រួសារដែលបានទទួលសម្បទានដីសង្គមកិច្ច នៅឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី
- បានបញ្ចូលព័ត៌មានក្នុងតារាងតាមដាន និងវាយតម្លៃរបស់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារនៅខេត្តកោះកុង និងខេត្តក្រចេះ ដោយបានរៀបចំតារាងបញ្ជីឈ្មោះអ្នកទទួលដីចំនួន ៣០៣ គ្រួសារ បញ្ចូលរូបថតផ្ទះឈើ និងផ្ទះថ្មចំនួន ២៧០ ខ្នង និងបញ្ចូលសមាជិកគ្រួសារដែលបានជួបសម្ភាសន៍ចំនួន ៧៤ គ្រួសារ
- បានបញ្ចប់ការងាររៀបចំផែនការប្រើប្រាស់ដី និងប្លង់បែងចែកដីឡូត៍លំនៅឋាន និងដីឡូត៍កសិកម្ម ព្រមទាំងបញ្ចូលឈ្មោះគ្រួសារដែលបានទទួលសម្បទានដីសង្គមកិច្ចចំនួន ១១៣ គ្រួសារ ចូលក្នុងផែនទីប្រើប្រាស់ដី បញ្ចូលឈ្មោះចូលក្នុងតារាង ថតចម្លងសៀវភៅគល់បញ្ជី និងបញ្ជីឈ្មោះរបស់អ្នកទទួលបានសម្បទានដីសង្គមកិច្ច ដោយមានស្នាមមេដៃនៅថ្ងៃចាប់ឆ្នោតចំនួន ១១៣

គ្រួសារ ព្រមទាំងរូបថតអ្នកទទួលសម្បទានដីសង្គមកិច្ចចំនួន ១០៥ សន្លឹក ស្ថិតនៅភូមិតីឡូលេខ ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់អំពីស្ថានភាពរស់នៅរបស់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ នៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ចំនួន ១១៨ គ្រួសារ ដែលបានមករស់នៅជាអចិន្ត្រៃយ៍ ចំនួន ១១៥ គ្រួសារ និងមិនអចិន្ត្រៃយ៍ចំនួន ០៣ គ្រួសារ លើផ្ទៃដីសរុបទំហំ ៦១,៦៤ ហិកតា និង បានថតរូប ទីតាំងដីឡូត៍លំនៅឋាន ចំនួន ២៤០ ឡូត៍ សម្រាប់តាមដានការប្រើប្រាស់ និងការចូល មករស់នៅរបស់ពួកគាត់ និងបានរៀបចំផែនការប្រើប្រាស់ដី និងប្លង់បែងចែកដីឡូត៍លំនៅឋាន និងកសិកម្ម ដោយបានប្រមូលគល់បញ្ជីសន្លឹកឆ្នោតចំនួន ៣០៤ សន្លឹក បញ្ជីឈ្មោះគ្រួសារដែល បានទទួលសម្បទានដីសង្គមកិច្ច ផែនទីទីតាំងសម្បទានដីសង្គមកិច្ចស្ថិតនៅក្នុងឃុំស្វាយជ្រះ ស្រុក ស្នួល និងឃុំក្បាលដំរី ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ។

## ៧.៣- ការអភិវឌ្ឍតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា

- បានសាងសង់ផ្ទះចំនួន ៣៨ ខ្នង រួចរាល់ជាស្ថាពរ នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដោយសហការជាមួយអគ្គិសនីកម្ពុជា
- បាន និងកំពុងសាងសង់ផ្ទះជូនគ្រួសារយោធិនដែលឈរជើងការពារតាមបណ្តោយព្រំដែនទិស ខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជាសរុបចំនួន ៥៥០ ខ្នង ដែលក្នុងនោះខេត្ត ព្រះវិហារចំនួន ២៥០ ខ្នង និងខេត្តឧត្តរមានជ័យចំនួន ៣០០ ខ្នង និងបានចូលរួមជាមួយ គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ និងវាយតម្លៃការផ្គត់ផ្គង់គ្រឿងបង្គុំ និងសម្ភារៈ សាងសង់ផ្ទះប៉ុតចំនួន ៥៥០ ខ្នង
- បានចុះបញ្ជីដីនិងផ្តល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុបានចំនួន ១០ ភូមិ នៅខេត្ត ព្រះវិហារ ស្មើនឹង **៣.៣៩៧** ក្បាលដី ត្រូវនឹង **៣.១៣៦** គ្រួសារ លើផ្ទៃដី **១.៣៧៧,៥៦** ហិកតា
- បានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដល់គ្រួសារយោធិន និងនគរបាលដែលកំពុង ឈរជើងការពារបូរណភាពទឹកដីនៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃ ព្រះរាជាណាចក្រកម្ពុជា ចំនួន **៦៥៨** គ្រួសារ ស្មើនឹង **៦៦៧** ប័ណ្ណ នៅលើផ្ទៃដីទំហំ **២៦៦,២៧** ហិកតា ស្ថិតនៅភូមិសែនរុងរឿង ២ សែនរុងរឿង ៣ សែនរុងរឿង ៤ និងភូមិតេជោមរកត ឃុំ មរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ
- បាន និងកំពុងគូសផែនទីទីតាំងសម្បទានដីសង្គមកិច្ចនៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ
- បានជួបប្រជុំពិភាក្សានៅសាលាខេត្តស្វាយរៀង ស្តីពីការរៀបចំផែនការសាងសង់ផ្ទះក្នុង គោលដៅសម្បទានសង្គមកិច្ចជូនគ្រួសារយោធិន និងនគរបាលដែលកំពុងឈរជើងការពារ នៅតាមបណ្តោយព្រំដែននៃខេត្តស្វាយរៀង។

## ៧.៤-កម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ

- បានចុះពិនិត្យ សិក្សា និងធ្វើអត្តសញ្ញាណកម្មដីរដ្ឋលម្អិតក្នុងទីតាំង ដែលបានស្នើសុំសម្បទានដីសង្គមកិច្ចរបស់ប្រជាពលរដ្ឋចំនួន ៧៥០ គ្រួសារ លើផ្ទៃដីទំហំ ៥.២០០ ហិកតា នៅឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ និងប្រជាពលរដ្ឋចំនួន ៥០៤ គ្រួសារ ដែលមកពីឃុំព្រះអណ្តូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ស្នើសុំដីសម្បទានសង្គមកិច្ចនៅខេត្តក្រចេះ ដោយបានស្នើសុំឱ្យអាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធ មេឃុំ កំណត់អត្តសញ្ញាណកម្មដី និងកំណត់មុខសញ្ញាអ្នកទទួលដីឡើងវិញដោយផ្អែកលើអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ និងប្រកាសលេខ ២០០ ដនស/ប្រក ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៣ និងស្នើសុំឱ្យរៀបចំយន្តការដើម្បីកសាងផែនទីទីតាំងស្នើសុំ ដោយមានការចូលរួមពីការិយាល័យកសិកម្ម និងការិយាល័យភូមិបាលស្រុក សង្កាត់រដ្ឋបាលព្រៃឈើ និងមេភូមិ
- បានចូលរួមរៀបចំតារាងបញ្ជីឈ្មោះអ្នកទទួលសម្បទានដីសង្គមកិច្ចជាក់ស្តែង ក្នុងចំណោម ៩៩៨ គ្រួសារ ដែលបានដាក់ពាក្យស្នើសុំដីសម្បទានសង្គមកិច្ចនៅក្នុងឃុំកំពង់ដំរី និងឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ បានចំនួន ៧៨៦ គ្រួសារ និងបានរៀបចំតារាងបញ្ជីឈ្មោះអ្នកទទួលដីសម្បទានសង្គមកិច្ច ជាក់ស្តែងនៅក្នុងចំណោម ៦៦ គ្រួសារ ដែលបានបាត់ឈ្មោះចេញពីបញ្ជីលើកទី២ របស់អ្នកទទួលសម្បទានដីសង្គមកិច្ច ៩៩៨ គ្រួសារ
- បាន និងកំពុងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកទទួលដីពិតប្រាកដចំនួន ៤២ គ្រួសារ លើសំណើសុំរបស់ប្រជាពលរដ្ឋចំនួន ៤០៣ គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋ ៩៩៨ គ្រួសារ និងក្រុម ៣៥៣ គ្រួសារ ដែលបានស្នើសុំសម្បទានដីសង្គមកិច្ច នៅចំណុចភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។

## ៧.៥-គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហាន២ (LASED II)

- បានចុះហត្ថលេខាជាមួយអង្គការ GIZ លើកិច្ចព្រមព្រៀងសហប្រតិបត្តិការរបស់គម្រោងលើក **កម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅប្រទេសកម្ពុជាជំហាន ២**
- បាន និងកំពុងរៀបចំតារាងបញ្ជីឈ្មោះ និងបញ្ចូលព័ត៌មានពាក់ព័ន្ធរបស់អ្នកទទួលសម្បទានដីសង្គមកិច្ចពីគម្រោង LASED បានចំនួន ១៥០ គ្រួសារ នៅក្នុងចំណោម ៤០០ គ្រួសារ នៅឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- បានប្រកាសតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដល់គ្រួសារដែលទទួលបានសម្បទានដីសង្គមកិច្ចចំនួន ៨៨៥ គ្រួសារ ស្ថិតនៅឃុំសំបុក និងឃុំចង្រ្កង់ ស្រុកចិត្របុរី ខេត្តក្រចេះ លើផ្ទៃដីសរុបទំហំ ៣.៩០៦ ហិកតា ស្មើនឹង ២.០០០ ឡូត៍ និងកំពុងវាស់វែងក្បាលដីដើម្បីចេញប័ណ្ណកម្មសិទ្ធិចំនួន ១.១៨៦ ក្បាលដី ក្នុងចំណោម ១.៥១០ ក្បាលដី

- បានចុះពិនិត្យ និងប្រមូលទិន្នន័យអំពីស្ថានភាពនៃការតាំងទីលំនៅ ធ្វើបច្ចុប្បន្នភាពផែនទី និងការប្រើប្រាស់ដីដែលបានបែងចែកជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅនៅឃុំចំបក់ ស្រុកព្រែក-ប្រសព្វ ខេត្តក្រចេះ ដោយបានសាកសួរព័ត៌មានអ្នកទទួលបានដីសម្បទានសង្គមកិច្ចចំនួន ៣២ គ្រួសារ ក្នុងចំណោម ៤០០ គ្រួសារ ចំពោះ ៣ គ្រួសារ បានតែដីកសិកម្ម
- បានចុះពិនិត្យ និងប្រមូលទិន្នន័យអំពីស្ថានភាពនៃការតាំងទីលំនៅ ធ្វើបច្ចុប្បន្នភាពផែនទី និងការប្រើប្រាស់ដីដែលបានបែងចែកក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅនៅឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ ដោយសួរព័ត៌មាន និងថតរូបតាមផ្ទះបានចំនួន ១០១ គ្រួសារក្នុងចំណោម ២៩៦ គ្រួសារ ស្មើនឹង ១០១ ឡូត៍ ថតដីឡូត៍លំនៅឋាន បានចំនួន ១៩៥ ឡូត៍ និងដីឡូត៍កសិកម្មបានចំនួន ៣៨៦ ឡូត៍ ដោយបានដៅសម្គាល់លេខឡូត៍លំនៅឋាន និងដីឡូត៍កសិកម្មក្នុងផែនទីប្រើប្រាស់ដី
- បានសម្ភាសន៍ប្រជាពលរដ្ឋ ដើម្បីសិក្សាពីកម្រិតជីវភាពរស់នៅពិតប្រាកដរបស់ពួកគាត់ ក្រោយពីទទួលបានសម្បទានដីសង្គមកិច្ចក្នុងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺចំនួន ៣២១ គ្រួសារ ក្នុងចំណោម ៤២៤ ឃុំក្រាំងល្វា ឃុំឈានឡើង និងឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងចំនួន ៥៨៥ គ្រួសារ ក្នុងចំណោម ៨៥៨ គ្រួសារ។

## ៨-ការងារយេនឌ័រ

- បានរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងការចុះពិនិត្យតាមដានការអនុវត្តការងារយេនឌ័រនៅតាមបណ្តារាជធានី ខេត្តចំនួន **១០** លើក សិក្ខាកាមចូលរួមសរុប **២៧៧** នាក់ (ស្រ្តី ៧៦ នាក់) ដែលក្នុងនោះរួមមាន ÷
  - បានចុះតាមដានត្រួតពិនិត្យការអនុវត្តអនុសញ្ញាស៊ីដ ៥២ ចំណុច ការបញ្រ្ជាបយេនឌ័រ និងដីធ្លី ការផ្សព្វផ្សាយអនុសាសន៍ ៦ ចំណុចរបស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** ដល់មន្រ្តីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ចំនួន ០៧ គឺនៅខេត្តឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង (០២ លើក) រតនគិរី (០២ លើក) មណ្ឌលគិរី កំពង់ធំ និងខេត្តប៉ៃលិន ដែលមានសមាជិកចូលរួមសរុបចំនួន **១៧៦** នាក់ (ស្រ្តី ៧៦ នាក់)
  - បានរៀបចំសិក្ខាសាលា ស្តីពីការបញ្រ្ជាបយេនឌ័រនិងដីធ្លី អ្នកចូលរួមសរុបចំនួន **១០១** នាក់
  - បានរៀបចំអបអរសាទរទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ ២០១៦ ខួបទី ១០៥។

## ៩-ការងារសហប្រតិបត្តិការ

ក្រសួងបាននិងកំពុងបន្តសហការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលរួមមាន÷

ក. **ការងាររដ្ឋបាលដីធ្លី:** (1)-កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជាសហការជាមួយអង្គការ GIZ អាល្លឺម៉ង់ (2)-គម្រោងស្តារនិងធ្វើឱ្យប្រសើរឡើងវិញនូវបណ្តាញរយៈកម្ពស់នៅកម្ពុជាដែលគាំទ្រដោយរដ្ឋាភិបាលវៀតណាម (3)-សមាគមអ្នកច្បាប់ជប៉ុន Shiho Shohi គាំទ្រលើការងារចុះបញ្ជីអចលនវត្ថុនិងសិទ្ធិប្រត្យក្សលើអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី។

ខ. **ការងារលំនៅឋាន :** (1)-គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) គាំទ្រដោយធនាគារពិភពលោក និងអង្គការ GIZ។

គ. **ការងាររៀបចំដែនដី :** (1)-គម្រោងកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងទីក្រុង ទីប្រជុំជន គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (2)-កម្មវិធីអនុវិស័យរៀបចំដែនដីដែលគាំទ្រដោយអង្គការ GIZ។

ច. **ការងារសំណង់:** (1)-សមាគមគ្រប់គ្រងសំណង់ក្លូប៉េ (CMAK) (2)-មូលនិធិ TEMASEK នៃប្រទេសសិង្ហបុរី (3)-សមាគមអ្នកសាងសង់កម្ពុជា (4)-Royal Institution of Chartered Surveyors និង International Business Chamber of Cambodia (RICS & IBC) (5)-សភាពាណិជ្ជកម្មសហភាពអឺរ៉ុបប្រចាំកម្ពុជា (EUROCHAM)។

**១០-ការងារអភិវឌ្ឍសេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ**

- បានសម្របសម្រួល និងគាំទ្រគម្រោងស្នើសុំវិនិយោគចំនួន ៣០ ក្រុមហ៊ុន លើវិស័យឧស្សាហកម្ម និងកម្មន្តសាល ដែលបានធ្វើការចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានទុនវិនិយោគចំនួន **១១៤.៧៦២.០៩៤** ដុល្លារអាមេរិក ដែលអាចបង្កើតការងារបានចំនួន **៤២.៥៨៥** កន្លែង។

**១១-ការងារលទ្ធកម្ម**

គម្រោងលទ្ធកម្មសរុបសម្រាប់ឆ្នាំ ២០១៦ មានចំនួន ៤១ គម្រោង ក្នុងនោះ÷

- បានអនុវត្តនីតិវិធីទូទាត់ចំនួន ៣២ គម្រោង
- បានស្នើសុំទិដ្ឋាការលើឯកសារដេញថ្លៃពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០១ គម្រោង
- គម្រោងដែលមិនអាចអនុវត្តបានចំនួន ០៨ គម្រោង។

**III-ទិសដៅការងារបន្ត**

ជាទិសដៅដែលក្រសួងនឹងត្រូវបន្តអនុវត្ត និងយកចិត្តទុកដាក់ជំរុញការអនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលបានចូលជាធរមាន។ ក្រសួងនឹងបន្តជំរុញការអនុវត្ត និងរៀបចំដូចជា÷

**១.ការអភិវឌ្ឍស្ថាប័ន**

១.១. ការងារគ្រប់គ្រងមន្ត្រី

- បន្តពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីរាជការក្រោមឱវាទក្រសួង
- រៀបចំបែបបទដំឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ជូនមន្ត្រីរាជការ។

## ១.២-ការងារផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច

- បន្តជំរុញការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋបាលកណ្តាល និងចំណូលរបស់មន្ទីរដ.ន.ស.សរាជធានី ខេត្តផ្តល់ជូនក្រសួង
- បន្តពង្រឹង និងអនុវត្តការងារថវិកាកម្មវិធីពេញលេញឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំការងារបៀវត្សរ៍ប្រចាំខែជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា។

## ១.៣.ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

- បើកវគ្គបណ្តុះបណ្តាលថ្នាក់ពិសេសមធ្យមសុរិយោដីជំនាន់ទី ៨ និងវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងរៀបចំដែនដីជំនាន់ទី ៣
- បើកវគ្គបំប៉នវិជ្ជាជីវៈពាក់ព័ន្ធនឹងវិស័យការងាររបស់ក្រសួងដល់មន្ត្រីនៅថ្នាក់ក្រោមជាតិ
- បន្តបើកវគ្គបណ្តុះបណ្តាលច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងវិស័យដីធ្លីដល់ក្រុមប្រឹក្សាក្រុង ស្រុកក្នុងខេត្តបន្ទាយមានជ័យ
- បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារសំខាន់ៗនៃគោលនយោបាយដីធ្លី និងលិខិតបទដ្ឋានថ្មីៗមួយចំនួនពាក់ព័ន្ធនឹងវិស័យដីធ្លីដល់អាជ្ញាធរដែនដីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញជុំវិញរាជធានី ខេត្តចំនួន ១៥ វគ្គ
- បើកវគ្គបំប៉នការងារសុរិយោដីចំនួន ០១ វគ្គ វគ្គបំប៉នការងារសំណង់ចំនួន ០១ វគ្គ និងវគ្គបំប៉នការងាររៀបចំដែនដីនិងនគរូបនីយកម្មចំនួន ០១ វគ្គ។

## ១.៤.ការងារសវនកម្ម និងអធិការកិច្ច

- អនុវត្តការងារសវនកម្មតាមផែនការ និងតាមដានការអនុវត្តការងារសេវាសាធារណៈសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៧
- ចុះធ្វើអធិការកិច្ចនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងនៅតាមការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ តាមផែនការឆ្នាំ ២០១៧ និងធ្វើអធិការកិច្ចតាមពាក្យបណ្តឹង
- បន្តចុះអធិការកិច្ច និងតាមដានអនុវត្តច្បាប់ គោលការណ៍ ការណែនាំ និងការងារបច្ចេកទេសសុរិយោដីនៅតាមបណ្តាមន្ទីររាជធានី ខេត្ត និងការិយាល័យភូមិបាលក្រុង ស្រុក ខណ្ឌ
- បន្តចុះពិនិត្យ ស្រាវជ្រាវបណ្តឹងរបស់ប្រជាពលរដ្ឋតាមបណ្តាញសារព័ត៌មាន និងតាមការបញ្ជារបស់ថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងការងារបច្ចេកទេសសុរិយោដី
- បន្តតាមដានលើការងារបច្ចេកទេសសុរិយោដី និងការអនុវត្តច្បាប់ លិខិតបទដ្ឋាននានា។

## ១.៥. ការគាំទ្រការងារវិមជ្ឈការ និងវិសហមជ្ឈការ

- បន្តសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងការបន្តអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមរយៈការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយទាំង ៣៦ ក្រុង ខណ្ឌ
- បន្តពិនិត្យកែសម្រួលមុខសញ្ញា និងតម្លៃសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បន្តសហការជាមួយអគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងការប្រមូលពន្ធប្រថាប់ត្រាពីការផ្ទេរកម្មសិទ្ធិ និងការចុះបញ្ជីដំបូង
- បន្តសហការជាមួយរដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ។

## ២. ការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្ត

**បន្តជំរុញរៀបចំសេចក្តីព្រាង៖**

### ក. ការងារសុរិយោដី

- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ភូមិបាលឆ្នាំ ២០០១
- ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជីដោយមូលហេតុមោឃភាព ឬការលុបចោល ឬការរំលាយនូវកិច្ចសន្យាដែលបង្កើតអានុភាពផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ និងពន្ធប្រថាប់ត្រា
- ប្រកាសស្តីពីការកំណត់ថ្លៃអតិបរិមារបស់អគារដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់
- ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- សេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ដែលពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការវាស់វែង និងការផលិតផែនទី និងលើការធ្វើអាជីវកម្មវាស់វែង និងការផលិតផែនទី។

### ខ- ការងាររៀបចំដែនដី និងនគរូបនីយកម្ម

- ច្បាប់ ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម
- ច្បាប់គ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសអន្តរក្រសួង ស្តីពីការពិន័យអន្តរកាលចំពោះបទល្មើស សម្រាប់ការអភិវឌ្ឍអចលនវត្ថុ
- ប្រកាសអន្តរក្រសួង ស្តីពីការចាត់ចែងចំណូលដែលបានមកពីការពិន័យចំពោះបទល្មើសសម្រាប់ការអភិវឌ្ឍអចលនវត្ថុ
- ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការពិន័យអន្តរកាល ការបង់ប្រាក់ពិន័យ ការគ្រប់គ្រង បង្កាន់ដៃបង់ប្រាក់ពិន័យចំពោះបទល្មើសនៃការអភិវឌ្ឍអចលនវត្ថុ
- ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ច សម្រាប់ការអភិវឌ្ឍអចលនវត្ថុ
- ប្រកាស ស្តីពីការអភិវឌ្ឍ និងសាងសង់បុរី

- ប្រកាស ស្ដីពីការកំណត់ថ្លៃ គម្លាត នគរូបនីយកម្មសម្រាប់ការអភិវឌ្ឍអចលនវត្ថុ
- សេចក្ដីសម្រេច ស្ដីពីនីតិវិធីនៃការកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ
- សេចក្ដីសម្រេច ស្ដីពីនីតិវិធីនៃការកសាងផែនការរៀបចំដែនដីតាមតំបន់
- សេចក្ដីសម្រេច ស្ដីពីនីតិវិធីនៃការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត
- សៀវភៅណែនាំបច្ចេកទេស ស្ដីពីការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត
- សៀវភៅណែនាំបច្ចេកទេស ស្ដីពីការកសាងប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- សេចក្ដីណែនាំ ស្ដីពីការរៀបចំរបាយការណ៍វាយតម្លៃគម្រោងស្នើសុំលិខិតអនុញ្ញាតសាងសង់ និងការអភិវឌ្ឍ
- ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុង។

**គ- ការងារសំណង់**

- ច្បាប់សំណង់
- អនុក្រឹត្យ ស្ដីពីលិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ
- ប្រកាស ស្ដីពីនីតិវិធី និងលក្ខខណ្ឌនៃការវាយតម្លៃ និងការចុះបញ្ជីរូបវន្តបុគ្គល នីតិបុគ្គលធ្វើអាជីវកម្មលើសេវាកម្មបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ និងត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់
- ប្រកាស ស្ដីពីប្រព័ន្ធការងារគ្រប់គ្រងគម្រោងសាងសង់
- ប្រកាស ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណដល់អ្នកត្រួតពិនិត្យ/បញ្ជាក់ការងារសាងសង់
- ប្រកាស ស្ដីពីការត្រួតពិនិត្យ វិភាគ វាយតម្លៃ ធ្វើកោសល្យវិច័យលើសំណង់ និងផ្ទៀងផ្ទាត់ការសាងសង់
- ប្រកាស ស្ដីពីការគ្រប់គ្រង និងត្រួតពិនិត្យការដ្ឋានសំណង់អាគារ
- ប្រកាសអន្តរក្រសួង ស្ដីពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ
- សេចក្ដីណែនាំ ស្ដីពីការរៀបចំគណៈកម្មការគ្រប់គ្រងបុរី ឬអគារសហកម្មសិទ្ធិ និងការរៀបចំបទបញ្ជាផ្ទៃក្នុងនៃបុរី ឬ អគារសហកម្មសិទ្ធិ។

## ៣.ការផ្ដល់សេវាសាធារណៈតាមច្រកចេញចូលតែមួយ

- បន្តធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធនឹងសេវាសាធារណៈរបស់ក្រសួងឱ្យស្របតាមតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ និងធុរជន
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងទិន្នន័យ (Data Base) នៅតាមមន្ទីររាជធានី ខេត្ត

- បញ្ចូលឯកសារគតិយុត្ត កម្រៃសេវារយៈពេលនៃការផ្តល់សេវា មធ្យោបាយទំនាក់ទំនង និង ទីតាំងសេវាក្នុងគេហទំព័ររបស់ក្រសួង។

## ៤.ការងាររដ្ឋបាលដីធ្លី

- បន្តជំរុញចេញប័ណ្ណឱ្យបានឆាប់នូវទិន្នន័យសេសសល់ពីការអនុវត្តបទបញ្ជាលេខ ០១ និងទិន្នន័យ ដែលនៅសេសសល់ពីការអនុវត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីក្នុងឆ្នាំ ២០១៦ និងបន្តអនុវត្តផែនការ ឆ្នាំ ២០១៧ ដោយធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធឱ្យសម្រេចបានចំនួន ៤០០.០០០ ក្បាលដី ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឱ្យបាន ១០ សហគមន៍ និងការចុះបញ្ជីដីរដ្ឋ ពិសេសដី រដ្ឋជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ចដែលបានត្រួតពិនិត្យរួចឱ្យបាន ១៥ ម៉ឺនហិកតា ហើយខិតខំ ជម្រះទិន្នន័យក្បាលដី ចុះបញ្ជីដីដាច់ដោយដុំ
- បន្តដោះស្រាយវិវាទដីធ្លី និងគាំទ្រផ្នែកគតិយុត្ត និងបច្ចេកទេសដល់ក្រុមដោះស្រាយវិវាទទាំង ៣៦ ក្រុម និង ២៥ ក្រុមចល័ត
- ចុះស្រង់ទិន្នន័យតាមភូមិសាស្ត្រ ចំនួន ២.៥០០ ចំណុច នៅខេត្តប៉ៃលិន បាត់ដំបង និងខេត្ត បន្ទាយមានជ័យ
- ចុះស្រង់ទិន្នន័យព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ចំនួន ៦៥ ឃុំ សង្កាត់ នៅខេត្តកំពង់ឆ្នាំង
- បន្តចុះវាស់វែងបណ្តាញបង្គោលប្រឹថពីវិភាគលំដាប់ទី ២ និងទី ៣ ចំនួន ៣២ បង្គោល និងបណ្តាញ រយៈកម្ពស់ ចំនួន ៧១ បង្គោល ( ១១០ គីឡូម៉ែត្រ) នៅខេត្តកំពង់ធំ
- បន្តកិច្ចសហការអនុវត្តគម្រោងស្តារ និងធ្វើឱ្យប្រសើរឡើងនូវបណ្តាញរយៈកម្ពស់នៅកម្ពុជា
- បន្តរៀបចំអភិវឌ្ឍន៍បន្ថែមលើប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យចុះបញ្ជីដីធ្លី ដែលមានស្រាប់ពីកម្មវិធី Microsoft Access ទៅកម្មវិធី Open Source ដើម្បីឆ្លើយតបទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ថ្មីៗ (ក្រមរដ្ឋប្បវេណី) និងដើម្បីពន្លឿនការផ្តល់សេវាចុះបញ្ជីដីធ្លី
- បន្តពង្រឹងការទទួលខុសត្រូវ និងសមត្ថភាពជំនាញរបស់មន្ត្រី តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាបន្តបន្ទាប់ ស្របតាមការអនុម័តថ្មីៗនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹង ដីធ្លី និងស្របតាមការវិវឌ្ឍន៍នៃបច្ចេកវិជ្ជាទំនើប
- ពង្រឹងអភិបាលកិច្ចល្អដោយត្រៀនរំលឹកជាប្រចាំឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ អប់រំ បង្ការ ទប់ស្កាត់ និងមានវិធានការរដ្ឋបាល
- បន្តជំរុញការបញ្ជូនឯកសារចុះបញ្ជីដីធ្លី ដែលបានសម្រេចចុះបញ្ជីនៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត រួចហើយទៅរដ្ឋបាលសុរិយោដីពីរទៀត ដើម្បីធ្វើលេខាចារីក និងចរន្តការឱ្យបានស្របគ្នារវាងរដ្ឋបាល សុរិយោដីទាំងបីថ្នាក់

- លើកកម្ពស់ការចូលរួមរបស់ម្ចាស់ដី និងអ្នកពាក់ព័ន្ធ (ទាំងប្រជាពលរដ្ឋទូទៅ និងស្ថាប័នរដ្ឋនានា) ក្នុងសកម្មភាពអនុវត្តការចុះបញ្ជីដីធ្លី តាមរយៈការផ្សព្វផ្សាយគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដើម្បីបង្កើនការយល់ដឹងលើវិស័យដីធ្លីកាន់តែទូលំទូលាយ ព្រមទាំងបង្កើនជំនឿទុកចិត្តរបស់មហាជនមកលើប្រព័ន្ធចុះបញ្ជីដីធ្លីតាមរយៈការផ្តល់សេវាល្អ តម្លាភាព លឿន និងតម្លៃសមរម្យឆ្ពោះទៅរកវប្បធម៌នៃការចុះបញ្ជីដីធ្លីមួយប្រកបដោយប្រសិទ្ធភាព។

## ៥.ការងាររៀបចំដែនដីនិងនគរូបនីយកម្ម

### ៥.១-ការងារកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងថ្នាក់តំបន់

- បន្តចុះប្រមូលទិន្នន័យសម្រាប់ការកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ
- បន្តរៀបចំសំណុំឯកសារសេចក្តីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ ដើម្បីស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី
- បន្តរៀបចំឯកសារត្រៀមសម្រាប់កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់ការឯកភាពលើក្របខណ្ឌអភិវឌ្ឍតំបន់ទីក្រុងជុំវិញបឹងទន្លេសាប។

### ៥.២-ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

- បន្តចុះពិនិត្យការដ្ឋានសាងសង់ខ្លោងច្រកចូលឆ្នេរ ក្រុងព្រះសីហនុ
- បន្តចុះសិក្សារៀបចំប្លង់កែលម្អឆ្នេរអូរឈើទាល ក្រុងព្រះសីហនុ
- បន្តចុះប្រមូលទិន្នន័យក្នុងការសិក្សាប្លង់គោល និងផែនការប្រើប្រាស់ដីលើកោះរ៉ុង និងការងារធៀលដីស្បែកខ្លានៅកោះរ៉ុង
- បន្តចុះវាស់វែង និងស្រង់ទិន្នន័យការប្រើប្រាស់ដីបច្ចុប្បន្នភាពលម្អិតនៅឆ្នេរអូរត្រេះ
- បន្តពិនិត្យ និងកែសម្រួលប្លង់ស្ថាបត្យកម្មតួបកម្សាន្ត នៃគម្រោងកែលម្អតំបន់ឆ្នេរខ្សាច់កំសាន្ត ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បន្តគាំទ្របច្ចេកទេសកសាងផែនការប្រើប្រាស់ដីលម្អិតតំបន់បឹងព្រែកទប់ ក្រុងព្រះសីហនុ។

### ៥.៣- ការងារកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

- ជំរុញបញ្ចប់ឯកសារផែនការរៀបចំដែនដីខេត្តបាត់ដំបង និងខេត្តព្រះសីហនុ ដើម្បីស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី
- បន្តដំណើរការកសាងផែនការរៀបចំដែនដីខេត្តសៀមរាប។

### ៥.៤ -ការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក និងទីប្រជុំជន

- ជំរុញបញ្ចប់ការរៀបចំកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជនចំនួន ០៣ គឺ ក្រុងសៀមរាប ខេត្តសៀមរាប ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ទីប្រជុំជនអ្នកលឿង ខេត្តព្រៃវែង

- ជំរុញបញ្ចប់ការរៀបចំកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុកចំនួន ០៧ គឺ ក្រុងកំពង់ឆ្នាំង និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្រុកបវេល ខេត្តបាត់ដំបង ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល
- ជំរុញបញ្ចប់ការរៀបចំកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកចំនួន ០៣ គឺ ស្រុកលំផាត់ ស្រុកវើនសៃ ខេត្តរតនគីរី និងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- ជំរុញបញ្ចប់ការកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងកំពត ក្នុងខេត្តកំពត
- ជំរុញបញ្ចប់ប្លង់លម្អិតទីប្រជុំជនស្រុកចិត្របុរី ខេត្តក្រចេះ
- ជំរុញបញ្ចប់ការអនុម័តសេចក្តីព្រាងប្លង់គោល និងផែនការប្រើប្រាស់ដីក្រុងព្រះសីហនុ ក្រុងកែប ក្រុងខេមរភូមិន្ទ និងក្រុងកំពត

៥.៥-ការងារកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់÷

- ជំរុញបញ្ចប់ផែនការប្រើប្រាស់ដីនៅក្នុងឃុំស្រអែម និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ
- ចាប់ផ្តើមគាំទ្របច្ចេកទេសកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន ០២ នៅខេត្តត្បូងឃ្មុំ និង ០១ ឃុំ នៅខេត្តកំពត
- បន្តជំរុញថ្នាក់ក្រោមជាតិបញ្ចប់គម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ចំនួន ៤៣ ទីតាំង ក្នុងខេត្តចំនួន ០៤ ដែលនៅសេសសល់
- គាំទ្របច្ចេកទេសដោយសហការជាមួយធនាគារអភិវឌ្ឍអាស៊ី រៀបចំកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ចំនួន ២៤ ឃុំ ក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តព្រៃវែង ក្នុងក្របខណ្ឌកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធននឹងអាកាសធាតុ។

## ៦-ការងារសំណង់

- បន្ត និងជម្រុញការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់
- បន្តការចុះពង្រឹងផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់ដល់មន្ទីរដ.ន.ស.ស.រាជធានី ខេត្ត អាជ្ញាធរដែនដី ក្រុមហ៊ុនសិក្សាគម្រោងប្លង់ក្រុមហ៊ុនសាងសង់ ក្រុមជាងសំណង់ អ្នកផលិតនិងអ្នកផ្គត់ផ្គង់សម្ភារៈសំណង់
- បន្តប្រមូលចងក្រងទិន្នន័យសំណង់ទូទាំងប្រទេស និងខិតខំកែលម្អអំពីនីតិវិធីនៃកិច្ចការនេះឱ្យកាន់តែប្រសើរឡើង
- បន្តចុះតាមដានត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានសំណង់ ជាពិសេសការដ្ឋានសំណង់ធំៗ និងខ្ពស់ៗ
- បន្តពង្រឹងកិច្ចការការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សោភ័ណភាព ស្ថាបត្យកម្ម តាមរយៈការគ្រប់គ្រងលើការសិក្សាគម្រោងប្លង់ ការសាងសង់ និងការត្រួតពិនិត្យការដ្ឋានឱ្យស្របតាមស្តង់ដារបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងស្របតាមលិខិតអនុញ្ញាតរបស់ស្ថាប័នមានសមត្ថកិច្ច

- បន្តទប់ស្កាត់ការចេញលិខិតអនុញ្ញាតសាងសង់ ជួសជុលរុះរើ និងការប្តូរទ្រង់ទ្រាយចំពោះសំណង់គ្រប់ប្រភេទ ដែលមានលក្ខណៈស្ថាបត្យកម្មបម្រើឱ្យវប្បធម៌បរទេសហួសហេតុ
- បន្តបង្កើនប្រសិទ្ធភាពការងារ និងសម្រេចឱ្យបានស្របតាមបរិបថការងារលើការត្រួតពិនិត្យគម្រោងប្លង់ដែលស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើក បិទការដ្ឋានសាងសង់ ការចុះបញ្ជីប្រកបអាជីវកម្មរបស់រូបវន្តបុគ្គល សហគ្រាសក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- បន្តពង្រឹង និងខិតខំអនុវត្តផែនការយុទ្ធសាស្ត្រថវិកាតាមកម្មវិធីឱ្យបានទាន់ពេលវេលាស្របតាមលទ្ធផលរំពឹងទុក និងការប្រើប្រាស់ថវិកាឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នផ្សេងៗទាំងថ្នាក់ជាតិ អន្តរជាតិ និងអាជ្ញាធរពាក់ព័ន្ធនានា ពិសេសបណ្តាក្រុមហ៊ុនវិនិយោគ និងម្ចាស់សំណង់លើការងារវិស័យសំណង់ និងការងាររចងក្រងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យសំណង់
- បន្តបញ្ចូលស្ថាបត្យករចុះបញ្ជីជាស្ថាបត្យករ គ.ស.ក និងជាស្ថាបត្យករអាស៊ាន
- ជំរុញការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការកំណត់តម្លៃសេវាស្ថាបត្យកម្ម និងស្តង់ដារស្ថាបត្យកម្ម
- បន្តពង្រឹងនិងសហប្រតិបត្តិការលើសេវាកម្មស្ថាបត្យកម្មជាមួយសេវាកម្មស្ថាបត្យកម្មបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងការងារផ្សេងៗ។

## ៧.ការងារលំនៅឋាន

- បន្តអនុវត្តអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានលំនៅឋាន និងក្រុមហ៊ុនវើលប្រ៊ីដ៍ឡិនខូអិលធីឌី សម្ព័ន្ធភាពអាស៊ីដើម្បីសិទ្ធិលំនៅឋាន និងមូលនិធិអភិវឌ្ឍសហគមន៍លើការងារសាងសង់លំនៅឋានសាធារណៈនៅកម្ពុជា
- បន្តអនុវត្តអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានលំនៅឋាន និងអង្គការលំនៅឋានសម្រាប់មនុស្សជាតិកម្ពុជា និងអង្គការការីតាស់កម្ពុជា
- បន្តសហការជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំ ដើម្បីចុះពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំ និងចុះត្រួតពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាលសាលាខេត្ត និងមន្ទីរជុំវិញខេត្តត្បូងឃ្មុំ
- សហការជាមួយអាជ្ញាធរខេត្តបាត់ដំបង ក្នុងការចុះស្រង់ទិន្នន័យទីតាំងតំបន់សំណង់បណ្តោះអាសន្ននៅក្រុងបាត់ដំបង ខេត្តបាត់ដំបង

- សហការជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំក្នុងការចុះប្រមូលទិន្នន័យពីការអភិវឌ្ឍលំនៅឋាននៅខេត្តត្បូងឃ្មុំ
- បន្តសហការជាមួយក្រុមហ៊ុន ARAKAWA ក្នុងការរៀបចំគម្រោងអភិវឌ្ឍឡើងវិញអគារប៉ូឌីញ "ស"
- ត្រៀមចុះពិនិត្យទីតាំងជាក់ស្តែង សម្រាប់ធ្វើជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និងនគរបាល ដែលកំពុងឈរជើងការពារនៅតាមបណ្តោយព្រំដែន នៃខេត្តស្វាយរៀង ដើម្បី ១) សិក្សាភូមិសាស្ត្រ ផលសាស្ត្រ ប្រភពទឹក ដោយរកការឯកភាពពីគណៈកម្មការព្រំដែនសម្របសម្រួលជាមួយខេត្តក្បែរ ក្រោយពីបានការឯកភាពពីរាជរដ្ឋាភិបាល និងសិក្សាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ២) រកទីតាំងនៅតាម ស្រុក ឃុំ ដើម្បីបានការសម្រួលទីតាំងដែលមានលក្ខណៈសមស្របអាចចាប់ផ្តើមសាងសង់ផ្ទះបានទាន់ពេលវេលា
- បន្តសហការជាមួយក្រុមការងារខេត្តក្រចេះ ដើម្បីដោះស្រាយបញ្ចប់បញ្ហារបស់ប្រជាពលរដ្ឋចំនួន ៤០៣ គ្រួសារ ដែលមិនទាន់បានទទួលដីកន្លងមកដោយផ្សព្វផ្សាយជាសាធារណៈ ធ្វើអត្តសញ្ញាណកម្មអ្នកស្នើសុំដីចំនួន ៤០៣ គ្រួសារនេះឱ្យបានច្បាស់លាស់បន្ថែមទៀតស្របតាមនីតិវិធីសម្បទានដីសង្គមកិច្ច និងគ្រោងចុះសិក្សាទីតាំងដីនៅក្នុងស្រុកស្នួលសម្រាប់យកមកធ្វើការបែងចែកបន្ត ដើម្បីបញ្ចប់បញ្ហារបស់ក្រុមប្រជាពលរដ្ឋ ៩៩៨ គ្រួសារ និងក្រុមរបស់ប្រជាពលរដ្ឋ ៣៥៣ គ្រួសារ
- សហការជាមួយក្រុមការងារខេត្តក្រចេះ ចុះស្រង់ទិន្នន័យលេខឡូត៍ដីលំនៅឋាន និងកសិកម្មជាក់ស្តែងរបស់គ្រួសារដែលបានទទួលសម្បទានដីសង្គមកិច្ចចំនួន ២៩១ គ្រួសារ ក្នុងចំណោម ៩៩៨ គ្រួសារ នៅឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ដែលពុំទាន់បានកំណត់លេខឡូត៍ដីពីមុនមក ដើម្បីដាក់បញ្ចូលក្នុងផែនទីសរុបរួម សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងឱ្យបានច្បាស់លាស់
- គាំទ្រ និងជំរុញការធ្វើបច្ចុប្បន្នភាពការតាំងទីលំនៅរបស់គ្រួសារអ្នកទទួលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ក្នុងខេត្តកំពង់ស្ពឺ ក្រចេះ បាត់ដំបង កំពតពោធិ៍សាត់ កំពង់ឆ្នាំង ព្រះសីហនុ សៀមរាប ស្ទឹងត្រែង រតនគិរី និងខេត្តកោះកុង
- ប្រមូលទិន្នន័យអ្នកទទួលបានសម្បទានដីសង្គមកិច្ចរបស់យុទ្ធជន ដែលកំពុងឈរជើងនៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ
- ចូលរួមក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចរបស់កម្មវិធីសម្បទានដីសង្គមកិច្ចខេត្តស្វាយរៀង
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database System) របស់មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច
- គ្រោងរៀបចំការអប់រំផ្សព្វផ្សាយ ព្រមទាំងបង្កើតយន្តការរក្សាការពារ និងបង្ការការកេងចំណេញ និងទន្ទ្រានលើដីសម្បទានសង្គមកិច្ច
- ចុះពិនិត្យទីតាំងដីដែលអាចនៅសល់សម្រាប់បែងចែកបន្តក្នុងគោលដៅសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ នៅក្នុងខេត្តទាំង ១៣ គឺខេត្តក្រចេះ កំពង់ស្ពឺ កោះកុង

ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប ឧត្តរមានជ័យ កំពង់ធំ មណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង

- ជំរុញដល់ក្រុមការងារថ្នាក់ក្រោមជាតិ ចុះស្រាវជ្រាវត្រួតពិនិត្យ ស្រង់ព័ត៌មានដើម្បីសរុបសន្និធិដីរដ្ឋ ដែលមិនទាន់មានការកាន់កាប់ ក្នុងខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង កណ្ដាល តាកែវ និងខេត្តកំពតសម្រាប់សម្បទានដីសង្គមកិច្ចជូនកងកម្លាំងដែលជាកងទ័ព នគរបាល និងកងរាជអាវុធហត្ថ ដែលកំពុងបម្រើការនៅតំបន់ព្រំដែនកម្ពុជាជាប់ជាមួយប្រទេសជិតខាង
- បន្តពិនិត្យ និងរៀបចំរាល់សំណើ និងលិខិតដែលទាក់ទងនឹងការស្នើសុំដីសម្រាប់គោលដៅសម្បទានដីសង្គមកិច្ច
- បន្តតាមដានការងារសាងសង់ផ្ទះប៉ិតចំនួន ៥៥០ ខ្នង នៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

### ៩.ការងារសមភាពយេនឌ័រ

- បន្តចុះតាមដានការអនុវត្តការបញ្ជ្រាបយេនឌ័រនិងដីធ្លី និងផ្សព្វផ្សាយអនុសាសន៍ ៥២ ចំណុច និងអនុសាសន៍ ០៦ ចំណុចរបស់**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរានី ហ៊ុនសែន** តាមបណ្ដាខេត្ត ១១
- រៀបចំឯកសារសម្រាប់ទិវាបុណ្យអន្តរជាតិនារី ០៨មីនា ឆ្នាំ ២០១៧។

### ១០-ការងារអភិវឌ្ឍសេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ

- ត្រៀមបោះពុម្ពសៀវភៅទិន្នន័យស្ថិតិផ្លូវការប្រចាំឆ្នាំ ២០១៥
- បន្តកិច្ចការសម្របសម្រួលការងារអនុវិស័យដីធ្លី និងផ្នែកពាក់ព័ន្ធជាមួយដៃគូអភិវឌ្ឍន៍។

### ១១-ការងារលទ្ធកម្ម

- រៀបចំសរុបផែនការលទ្ធកម្មប្រចាំឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## III-សេចក្ដីសន្និដ្ឋាន

សរុបជារួមមក ក្រសួងសម្រេចបានសមិទ្ធផលការងារជាច្រើន ដែលស្ថិតក្នុងបេសកកម្មការងារជំនាញរបស់ខ្លួនជូនរាជរដ្ឋាភិបាល រួមមានការងាររដ្ឋបាលដីធ្លី ការងាររៀបចំដែនដី និងនគរូបនីយកម្ម ការងារលំនៅឋាន និងការងារសំណង់ ក៏ដូចជាការងារដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងទីតាំងដីសម្បទានសង្គមកិច្ច ការងារគ្រប់គ្រងមន្ត្រី ការពង្រឹងនិងការអភិវឌ្ឍស្ថាប័ន ការបណ្ដុះបណ្ដាលធនធានមនុស្ស ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានា ការធ្វើសវនកម្ម និងអធិការកិច្ច ការផ្ដល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលនិងចំណាយ ការងារកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងការងារយេនឌ័រ។ ជាមួយគ្នានេះដែរ ក្រសួងបានយកចិត្តទុកដាក់ជីវភាពរស់នៅរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដូចជាការលើកទឹកចិត្ត តាមរយៈការផ្ដល់ប្រាក់លាភការបន្ថែម

ដែលទទួលបានពីកម្រៃសេវានៃការផ្ដល់សេវាសាធារណៈ ការផ្ដល់គ្រឿងឥស្សរិយយស និងមេដាយការងារ ការដំឡើងឋានៈ រួមទាំងការធ្វើសមាហរណកម្មឋានន្តរស័ក្តិនិងថ្នាក់ និងការបង្កើតសមាគមមន្ត្រីរាជការក្រសួង ក្នុងគោលបំណងជួយសម្រាលការលំបាករបស់មន្ត្រីក្នុងពេលមានគ្រោះអាសន្ន។ ផ្ទុយមកវិញ ក្រសួងក៏មានវិធានការយ៉ាងតឹងរឹងចំពោះមន្ត្រីអសកម្មទាំងអស់ទាំងថ្នាក់កណ្ដាល និងថ្នាក់ក្រោមជាតិ ដូចជាការលុបឈ្មោះចេញពីក្របខ័ណ្ឌ ដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស និងវិធានការរដ្ឋបាលផ្សេងៗ។

លទ្ធផលដែលសម្រេចបានខាងលើនេះ គឺជាសមិទ្ធផលរួម ដែលបង្ហាញពីកម្លាំងសាមគ្គីឯកភាពផ្ទៃក្នុងរបស់ក្រសួងក្រោមការដឹកនាំនិងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងព្រមទាំងកិច្ចសហការអនុវត្តជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គភាពជំនាញពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការរួមចំណែកធ្វើឱ្យសម្រេចនូវកម្មវិធីនយោបាយដែលរាជរដ្ឋាភិបាលបានដាក់ចេញ ជាពិសេសការយកចិត្តទុកដាក់អនុវត្តកម្មវិធីកំណែទម្រង់នានា ដែលស្ថិតក្នុងអាណត្តិបេសកកម្មរបស់ក្រសួង។ ក្រៅពីការងារស្នូលខាងលើ ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញគ្រប់ថ្នាក់/ផ្នែកតែងយកចិត្តទុកដាក់អំពីសុខទុក្ខនិងជីវភាពរស់នៅរបស់មន្ត្រី ក៏ដូចជារបស់ប្រជាពលរដ្ឋទូទៅ។ ក្រសួងក៏បានចូលរួមឆ្លើយតបនឹងសំណូមពរ និងអនុសាសន៍ ឬចម្ងល់នានារបស់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈនានា បណ្ដាញប្រព័ន្ធផ្សព្វផ្សាយសង្គម (Facebook) របស់ក្រសួង និងតាមបណ្ដាញសារព័ត៌មាននានាផងដែរ៕

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  «ដើម្បីជូនជ្រាប»
- គ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  « ដើម្បីជូនជ្រាប និងសហការអនុវត្ត »
- ឯកសារ-កាលប្បវត្តិ